# *សិលាចារឹកភូមិជន្ទូសចាស់ K.១៤១៤*

*សិលាចារឹកនេះមានប្រភពមកពីទួលបុរាណមួយ ស្ថិតនៅក្នុងភូមិជន្ទូស ឃុំទួលគ្រើល ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ។ នៅសម័យក្រោយសង្គ្រាម ទីតាំងភូមិនេះជាកន្លែងប្រទាញប្រទង់គ្នាជាមួយខ្មែរក្រហម។ មកដល់ទសវត្សឆ្នាំ៨០ រដ្ឋការបានបង្កើតភូមិជន្ទូសថ្មី នៅក្បែរទីរួមស្រុកប្រាសាទបល្ល័ង្គបច្ចុប្បន្ន រួមទាំងទីតាំងផ្សេងៗទៀតដូចជាសាលាសំណាក់ វត្តជាដើមដោយដាក់ឈ្មោះដូចភូមិចាស់ទាំងស្រុង ដើម្បីឱ្យប្រជាពលរដ្ឋមករស់នៅកន្លែងថ្មីឱ្យមានអារម្មណ៍ថាដូចជាទីតាំងចាស់។ យ៉ាងនេះក្ដី ប្រជាពលរដ្ឋមួយចំនួនពុំបានផ្លាស់លំនៅទៅភូមិថ្មីឡើយ។*

*នៅភូមិជន្ទូសចាស់នោះ មានទីទួលមួយហៅថាទួលជន្ទូស ជាទីតាំងអ្នកតាចាស់ស្រុក។ នៅលើទីទួលនេះមានសង់រោងជាខ្ទមអ្នកតាចាស់ស្រុកមួយ ដែលមានជើងទម្របដិមាមួយចំនួន និងសិលាចារឹកមួយផ្ទាំងដែលចុះលេខ K.១៤១៤ មានទំហំ ២៩ស.ម. x ២៤ស.ម. x ៤ស.ម.។ «ជន្ទូស» ជាស្ថាននាមមួយដែលបន្សល់មកតាំងពីបុរាណ ដូចមានកស្តុតាងតាមរយៈសិលាចារឹកនេះដែលសរសេរជា «**ជនិល្វស**»។[១]*

*សិលាចារឹកនេះមានកាលបរិច្ឆេទនៅឆ្នាំ៨៨៧នៃមហាសករាជ ត្រូវនឹងគ្រិស្តសករាជ៩៦៥ ចារពីព្រះរាជបញ្ជារបស់ព្រះមហាក្សត្រ ត្រាស់បង្គាប់ម្រតាញខ្លោញស្រីនរបតីវីរវម្ម៌និងក្រុមមន្ត្រីជាច្រើនទៀត ទូលព្រះរាជបញ្ជាឱ្យដល់វាបម្នាក់ទៅពិនិត្យដីនិងភោគផលរបស់ប្រាសាទនៅឯជន្ទូស និងឱ្យប្រគល់ដីដែលមានជម្លោះត្រឡប់មកប្រាសាទវិញ ដោយសង់គោលនិងសិលាចារឹកដើម្បីកុំឱ្យមានជម្លោះជាថ្មីម្ដងទៀត។*

*មន្ត្រីឈ្មោះ **ម្រតាញខ្លោញស្រីនរបតីវីរវម្ម៌** នៅក្នុងសិលាចារឹកនេះ យើងធ្លាប់ប្រទះនៅក្នុងសិលាចារឹកពីរ គឺសិលាចារឹកវត្តតាព្រះយ៉ា K.១១៥២ និងសិលាចារឹកប្រាសាទចារ*

---

*[១] អត្ថបទនេះ ស្មេរធ្លាប់ចុះផ្សាយម្ដងរួចមកហើយនៅក្នុងទស្សនាវដ្ដីកម្ពុជសុរិយា លេខ២៤ ឆ្នាំ២០១៨។ កាលនោះ ស្មេរមិនបានទៅកាន់ទីតាំងនិងផ្ដិតសិលាចារឹកនោះដោយផ្ទាល់ឡើយ គឺបានសិក្សាអត្ថបទសិលាចារឹកនេះតាមរយៈសំណៅផ្ដិតរបស់សារមន្ទីរខេត្តកំពង់ធំតែប៉ុណ្ណោះ។ ក្រោយមក ស្មេរបានទៅកាន់ទីតាំងនិងផ្ដិតសំណៅសិលាចារឹក ទើបផ្ទៀងផ្ទាត់សារជាថ្មីនិងចុះផ្សាយនៅទីនេះ។*

*អត្ថបទដោយ៖ ហ៊ុន ឈុនតេង*

K.២៥៧។ សិលាចារឹកទាំងនេះបង្ហាញថា **មូតាញខ្លោញស្រីនរបតីវីរវម៌្ម** បម្រើការរាជការតាំងពីរាជ្យព្រះបាទរាជេន្ទ្រវម៌្មទេវ(រាជេន្ទ្រវម៌្ន ៩៤៤-៩៦៨គ.ស.) រហូតដល់រាជ្យព្រះបាទសូរ្យវម៌្មទេវទី១(សូរ្យវម៌្នទី១ ១០០២-១០៥០គ.ស.)។ ក្នុងសិលាចារឹកនេះបញ្ជាក់ថាលោកកំពុងបម្រើក្នុងរាជ្យព្រះបាទរាជេន្ទ្រវម៌្មទេវនាចុងស.វ.ទី១០។ តាមរយៈសិលាចារឹក K.២៥៧ ក្នុងរាជ្យព្រះបាទសូរ្យវម៌្មទេវទី១ មូតាញរូបនេះឡើងឋានៈនិងមានងារជា «**កំស្តែងស្រីនរបតីវីរវម៌្ម**»។

ចំពោះលក្ខណៈសំណេរនៅក្នុងសិលាចារឹកនេះហាក់ប្លែកបន្តិច ដ្បិតពាក្យមួយចំនួនដែលមានពីរព្យាង្គពុំប្រើវិធីតម្រួតទេ បែរជាប្រើវិធីសរសេរបន្តគ្នាទៅវិញ។ បើយើងពិនិត្យលើក្បួនសំណេរប្រព័ន្ធព្រាហ្មីក្តីនិងទេវនាគរីក្តី កាលណាមានព្យញ្ជនៈមួយនៅបន្ទាប់ពីព្យញ្ជនៈដែលមានសញ្ញាវិរាមនៅខាងលើ គេអាចសំយោគ(សរសេរត្រួតលើគ្នាឬភ្ជាប់គ្នាដោយលុបផ្នែកណាមួយ)ព្យញ្ជនៈពីរនោះចូលគ្នាបាន។ ឬម្យ៉ាងទៀតគេមិនសំយោគ រួចសរសេរបន្តគ្នាធម្មតាក៏បាន។ ឧ. कङ्कर និង कङ्‍कर ។ ករណីនេះ នាំឱ្យយើងអាចធ្វើបុនស្ថាបនកម្ម(Reconstruction) បានថាពាក្យខ្មែរបុរាណមួយនាសម័យមុនអង្គរដែលមានតួប្រកបខាងចុង គេអាចសរសេរបីរបៀបដូចជា **ផោង៑ ផោង្ង ផោងង, ទង៑ ទង្ង ទងង**។ ពាក្យជាទូទៅដែលឃើញច្រើនតែសរសេរជា **មន្ត្រី បន្ទូល សង្គោល** នៅក្នុងសិលាចារឹកនេះបែរសរសេរជា **មនិត្រិយ បនិទូល សង៑គោល**។ សូម្បីតែពាក្យ **អ្ជិ** ក៏សរសេរជា **អ ជិ** វិញដែរ។ ទាំងនេះជាលក្ខណៈផ្នែកសំណេរបុរាណមួយដែលគួរឱ្យកត់សម្គាល់។

### អត្ថបទដើមជាអក្សរខ្មែរទំនើប

១- [៨]៨៧គកតគិ[នវមិ]កេតិកត្តិក[អា]ទិ[ត្យវា]

២- វនុមានិវ្រះគាសនធូលិវ្រះបាទធូលិជេង៑

៣- វ្រះកម្រតេង៑អញ៑តម្រតាញ៑ខ្លោញ៑ត្រីន[រប]

៤- តិវិរវម៌្មនុកំស្តេង៑អញ៑រាជកុលមហាមនិ[ត្រិ]

៥- យនុខ្លោញ៑វលតខ្លោញ៑គ្នាង៑តប្វានិនុខ្លោញ៑វ

៦- លតខ្លោញ៑វង្វាង៑តប្វានិបិបនិទូលិវ្រះគាស

៧- នត[វាបិវាង៑] ប្រត្យយតប្រេមោកិគោជេភូ[ម្យា]

៨- ករវ្រះកម្រតេង៑អញ៑អាយិជនិល្វសិមនិវណ្ណ៌[]

អត្ថបទដោយៈ ហ៊ុន ឈុនតេង

៩- គ្រមផោងមនិ[អ្នកិនុ---]មានទុញ៉មនិ[អ្នកិវ្រះអញ៉]

១០- តិប្រេសងគោលិប្រគស្តុបិឱយិរិងតវ្រះកម្រ[តេ]

១១- ងអញ៉លេងវ្ំដាបិមានអបវាទអាយិជនិ[ល្វ]

១២- សិទៃ ភូម្យា[ករ]ស្រេនាទ្នុកិវ្រះតំម្រ្យតិវាបិ--

១៣- -កិតអជិវាបិ[លោ]ញនុវាបិបិត្ត--វាបិ-

១៤- --នុវាបិ[គ]និ-លិនុវាបិ[លោ]ញ៉ទៃយតិ

១៥- [---អត្ថបទដាច់---]

## អត្ថបទប្រែសម្រួល

ឆ្នាំ៨៨៧នៃមហាសករាជ ថ្ងៃ៩កើត ខែកត្តិក ថ្ងៃអាទិត្យ មានព្រះរាជសាសន៍ធូលីព្រះបាទធូលីជើងព្រះគម្តែងអញ ត្រាស់ដល់ម្រតាញខ្លោញស្រីនរបតីវីរវម្ម៌ កំស្តែងអញរាជកុលមហាមន្ត្រី ខ្លោញពលជាខ្លោញឃ្លាំងទាំងបួនថ្នាក់ ខ្លោញពលជាខ្លោញវង្វាងទាំងបួនថ្នាក់ គប្បីទូលព្រះរាជសាសន៍ឱ្យដល់វាបវាំងជាប្រត្យ័យ ប្រើឱ្យមកពិនិត្យដីនិងភោគផលរបស់ប្រាសាទនៅឯជន្ទូស។ (ដីដែល)ក្រុមពណ៌ាស្រម អ្នកបម្រើ និង--- ទិញនោះព្រះរាជាត្រាស់ប្រើឱ្យសង់គោលសិលាចារឹក គប្បីប្រគល់មកវិញដល់ប្រាសាទព្រះគម្តែងអញ ពុំគប្បីមានជម្លោះនៅឯជន្ទូសទៀត។ ដីនិងភោគផល ព្រមទាំងស្រែនៅនាទ្នុកព្រះដំរីវាប---ជាជីតាវាបលេនិងវាបបិត្ត-----និងវាបគន-- និងវាបលោញម្នាក់ទៀត---[អត្ថបទដាច់]---។

## វាក្យសព្ទ

| | |
|---|---|
| *វ្រះបាទធូលិជេងវ្រះកម្រតេងអញ៉* | ពាក្យជាឋានន្តររបស់ព្រះមហាក្សត្រ។ |
| *ម្រតាញខ្លោញ៉* | ឋានន្តរនាមនៃមេតម្រួតពលប្រចាំស្រុកនីមួយៗនៅសម័យអង្គរ និងមន្ត្រីថ្នាក់កណ្តាលជាច្រើនទៀតដែលបម្រើការក្នុងរដ្ឋបាលស៊ីវិល កងទ័ព និងសាសនា។[2] |

[2] វង់ សុធារ៉ា, ២០១៦។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

| | |
|---|---|
| ***កំស្តេងអញ*** | *ជាឋានន្តរនាមសម្គាល់បុគ្គលដែលស្ថិតនៅក្នុងវណ្ណៈអភិជន មន្ត្រីជាន់ខ្ពស់ មហាសេនាបតី អ្នកអង្គម្ចាស់ និងមន្ត្រីសង្ឃជាន់ខ្ពស់ផងដែរ[1]។* |
| ***ខ្លោញវល*** | *មេកងទ័ព។* |
| ***ខ្លោញគ្នាង*** | *ប្រធានឃ្លាំង។* |
| ***ខ្លោញរង្វាង*** | *ប្រធានផ្នែកសន្តិសុខ ប្រធានផ្នែកស៊ើបអង្កេត។* |
| ***ប្រត្យយ*** | *មន្ត្រីជំនិត មនុស្សជំនិត រាជបម្រើ។* |
| ***គោជេ*** | *ពិនិត្យមើលដើម្បីជម្រះ, ជម្រះ, ស៊ើបក្តី។* |
| ***វណ្ណាគ្រម*** | *ពណ៌ស្រម, ក្រុមមនុស្សឬបព្វជិតនៅក្នុងអាស្រម។* |
| ***អបវាទ*** | *ជម្លោះ, វិវាទ។* |

## *ឯកសារយោង*

*វង់ សុធារ៉ា,*

*២០១៦. សិលាចារឹកនៃប្រទេសកម្ពុជាសម័យអង្គរ. ការផ្សាយលើកទី២. ភ្នំពេញ។*

[1] វង់ សុធារ៉ា, ២០១៦។

*អត្ថបទដោយ៖ ហ៊ុន ឈុនតេង*

## បញ្ជីរូបភាព



ខ្ទមអ្នកតាចាស់ស្រុកនៅទួលជន្លួស



រូបសិលាចារឹក



សំណៅផ្តិតសិលាចារឹក (ផ្តិតដោយៈ ហ៊ុន ឈុនតេង)